**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

**សំណុំរឿងរដ្ឋប្បវេណីលេខ ៥០៧**
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣
**សាលក្រមរដ្ឋប្បវេណីលេខ ០៥៣ ឋ**
ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ៖ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣។
កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣។

**ចៅក្រម**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមជំនុំជម្រះ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអង្គសញ្ញាណភាគី**

ដើមចោទឈ្មោះ [redacted] **ស្រីនិច្ច** ភេទស្រី កើតថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៨៦ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

[redacted]។

**អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ [redacted]។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យផ្ទះលេខ [redacted]។

ចុងចម្លើយឈ្មោះ [redacted] **សំអុល** ភេទប្រុស កើតថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៨១ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

ទីលំនៅផ្ទះលេខ [redacted]។

**អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ៖**

លោកស្រី [redacted] ជាសមាជិក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ [redacted]។



Scanned with CamScanner

## អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃពាក្យបណ្ដឹងដែលដើមចោទទាមទារឱ្យតុលាការចេញ

១. ឱ្យដើមចោទឈ្មោះ [redacted] ស្រីនិច្ច លែងលះពីចុងចម្លើយឈ្មោះ [redacted] សំអុល។

២. ប្រគល់សិទ្ធិអំណាចមេបាលគ្រប់គ្រងកូនឱ្យទៅដើមចោទឈ្មោះ [redacted] ស្រីនិច្ច លើកូនឈ្មោះ [redacted] យ៉ានីន ភេទស្រី កើតថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ តាមសំបុត្រកំណើតលេខ ៤៦ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨។

៣. ឱ្យបែងចែកនៅទ្រព្យសម្បត្តិរួមនូវទឹកប្រាក់ចំនួន **២៥.០០០ (ពីរម៉ឺនប្រាំពាន់)** ដុល្លារអាមេរិក ជាពីរចំណែកស្មើគ្នា ដែលចុងចម្លើយបានយកទៅចងការប្រាក់។

៤. ឱ្យចុងចម្លើយឈ្មោះ [redacted] **សំអុល** បង់ផ្ដាច់នៅអាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន **៣០.០០០.០០០ (សាមសិបលាន)** រៀល។

### ខ. ដំណើររឿងក្ដី និងចំណុចវិវាទ

#### ខ.១. ការសង្ខេបអំពីរឿងក្ដី

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៥ ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ១៤ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ របស់រដ្ឋបាលឃុំស្វាជ្រុំ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ ក្រោយរៀបអាពាហ៍ពិពាហ៍ ដើមចោទ និងចុងចម្លើយមានកូនម្នាក់ឈ្មោះ [redacted] យ៉ានីន ភេទស្រី កើតថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧។ អំឡុងឆ្នាំ២០១៨ ដើមចោទ និងចុងចម្លើយបានទិញដីមួយកន្លែង ទំហំ ២៥ ម៉ែត្រ គុណ ១២០ ម៉ែត្រ ស្ថិតក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម តែក្រោយមកក្នុងឆ្នាំ២០២២ ក៏បានលក់ដីនោះវិញបានទឹកប្រាក់សរុបចំនួន ២៩.០០០ (ពីរម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក និងបានឯកភាពគ្នាដកប្រាក់ចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ដើម្បីប្រើប្រាស់សេវាផ្ទេរសិទ្ធិកាន់កាប់ ហើយទឹកប្រាក់នៅសល់បន្ទាប់ពីលក់ដីមានចំនួន ២៥.០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក។ ប្រាក់ដែលនៅសល់នេះ ចុងចម្លើយបានយកប្រាក់នេះទៅរកស៊ីចងការប្រាក់ ហើយបានយកប្រាក់ចំនួន ៤០០ (បួនរយ) ដុល្លារអាមេរិក មកប្រគល់ឱ្យដើមចោទជារៀងរាល់ខែចាប់ពីខែវិច្ឆិកា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ដោយប្រាប់ដើមចោទថា ជាប្រាក់ថ្លៃការប្រាក់ឱ្យគេ។ ប្រាក់ដែលបានពីការលក់ដី ចុងចម្លើយជាអ្នកគ្រប់គ្រងចាត់ចែង។ ដោយហេតុថា ការរស់នៅជាប្ដីប្រពន្ធមកដល់បច្ចុប្បន្ន មានភាពមិនចុះសម្រុងគ្នា ពោលគឺតាំងតែពីពេលរៀបអាពាហ៍ពិពាហ៍រហូតដល់បច្ចុប្បន្ន មានរយៈពេលជិត ៨ ឆ្នាំហើយ ដែលចុងចម្លើយមិនបានបំពេញតួនាទីជាមេគ្រួសារទេ។ ដោយមិនចង់បែកបាក់ ដើមចោទបានព្យាយាមពន្យល់ស្នើសុំឱ្យចុងចម្លើយធ្វើការកែប្រែខ្លួន ឈប់ដើរលេងយប់ មកបំពេញតួនាទីជាមេគ្រួសារ តែចុងចម្លើយមិនព្រមកែប្រែខ្លួនឡើយ ហើយពីមួយថ្ងៃទៅមួយថ្ងៃចុងចម្លើយតែងតែដើរលេងយប់ចូលផ្ទះយប់ជ្រៅជាញឹកញាប់ដោយមិនខ្វល់ពីសុខទុក្ខប្រពន្ធកូនឡើយ សូម្បីតែថ្ងៃសៅរ៍-អាទិត្យឈប់សម្រាក ក៏ចុងចម្លើយមិននៅផ្ទះដែរ មិនតែប៉ុណ្ណោះចុងចម្លើយតែងតែសុំដើមចោទលែងលះគ្នាជាច្រើនសារ ធ្វើឱ្យដើមចោទ និងកូនមិនបានទទួលភាពកក់ក្ដៅក្នុងនាមជាប្រពន្ធកូននោះទេ ហើយចុងចម្លើយតែងតែរករឿងបង្កជម្លោះគំរាមកំហែងមកលើដើមចោទ ដែលជាហេតុធ្វើឱ្យដើមចោទអស់មនោសញ្ចេតនារស់នៅជាប្ដីប្រពន្ធបន្តទៀត។



Scanned with CamScanner

១.២. អង្គហេតុដែលគ្មានវិវាទ៖ គ្មាន។

១.៣. អំពីចំណុចវិវាទ៖

១.៣.១. តើការលែងលះរវាងដើមចោទ និងចុងចម្លើយ មានមូលហេតុនៃការលែងលះដែរឬទេ?

១.៣.២. តើការសុំសិទ្ធិគ្រប់គ្រងកូនរបស់ដើមចោទមានមូលហេតុត្រឹមត្រូវដែរឬទេ?

១.៣.៣. តើការទាមទារឱ្យតុលាការបែងចែកទ្រព្យសម្បត្តិរួមចំនួន ២៥.០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក មានមូលហេតុត្រឹមត្រូវដែរឬទេ?

១.៣.៤. តើការទាមទាររបស់ដើមចោទលើអាហារកាតព្វកិច្ចបង់ផ្តាច់សម្រាប់ចិញ្ចឹមកូនពីចុងចម្លើយឈ្មោះ ហោ សំអុល ចំនួន ៣០.០០០.០០០ (សាមសិបលាន) រៀល ត្រឹមត្រូវដែរឬទេ?

១.៤. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ

១.៤.១. ស្តីពីចំណុចវិវាទទី១៖ ការលែងលះរវាងដើមចោទ និងចុងចម្លើយ

ក. ការអះអាងរបស់ដើមចោទ៖ នាងខ្ញុំនៅតែទាមទារលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] សំអុល ដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ ដដែល ដោយការពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៥ នាងខ្ញុំ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ១៤ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ត្រឹមត្រូវតាមផ្លូវច្បាប់។ ក្រោយពីបានរួមរស់ជាមួយគ្នាកន្លងមកគឺមានភាពមិនស្មូវចុះសម្រុងជាមួយគ្នាឡើយ ដោយចុងចម្លើយឈ្មោះ [redacted] សំអុល មិនបានបំពេញតួនាទីជាមេគ្រួសារទេ ហើយនាងខ្ញុំបានព្យាយាមពន្យល់គាត់ឱ្យធ្វើការកែប្រែខ្លួនដែល ប៉ុន្តែគាត់មិនបានកែប្រែខ្លួនឡើយ ហើយពីមួយថ្ងៃទៅមួយថ្ងៃគាត់តែងតែដើរលេងដល់យប់ជ្រៅហើយមិនចូលផ្ទះជាញឹកញាប់ ដោយមិនខ្វល់ពីសុខទុក្ខប្រពន្ធកូនឡើយ។ ហេតុនេះហើយ ទើបនាងខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងសុំលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] សំអុល តែម្តង។

ខ. ការអះអាងរបស់ចុងចម្លើយ៖ ខ្ញុំបាទមិនឯកភាពលែងលះជាមួយប្រពន្ធឈ្មោះ ជាតិ ស្រីនិច្ច ទេ ចំពោះដែលដើមចោទអះអាងនោះគឺជាអ្វីដែលមិនពិតទេ ខ្ញុំមិនបានប្រព្រឹត្តអំពើដូច្នេះទេ។

១.៤.២. ស្តីពីចំណុចវិវាទទី២៖ អំពីសិទ្ធិអំណាចមេបាលគ្រប់គ្រងកូន

ក. ការអះអាងរបស់ដើមចោទ៖ ក្រោយពីរៀបអាពាហ៍ពិពាហ៍មក នាងខ្ញុំ និងចុងចម្លើយឈ្មោះ [redacted] សំអុល មានកូនម្នាក់ឈ្មោះ [redacted] ម៉ានីន ភេទស្រី កើតថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ តាមសំបុត្រកំណើតលេខ ៤៦ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ នាងខ្ញុំសុំទាមទារនូវសិទ្ធិគ្រប់គ្រងក្រោយពីបានការលែងលះ សព្វថ្ងៃនាងខ្ញុំមានមុខរបរជាមន្ត្រីរដ្ឋបាលនៅរដ្ឋសភា។

ខ. ការអះអាងរបស់ចុងចម្លើយ៖ ចំពោះចំណុចនេះ ខ្ញុំបាទក៏មិនឯកភាពដែល សព្វថ្ងៃខ្ញុំបាទមានមុខរបរជាមន្ត្រីរដ្ឋបាលនៅរដ្ឋសភាដែរ។

១.៤.៣. ស្តីពីចំណុចវិវាទទី៣៖ ទឹកប្រាក់ចំនួន ២៥,០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក



Scanned with CamScanner

ក. ការអះអាងរបស់ដើមចោទ៖ ក្រោយពីរៀបអាពាហ៍ពិពាហ៍មក នាងខ្ញុំ និងចុងចម្លើយឈ្មោះ [redacted] សំអុល បានទិញដីមួយកន្លែងមានទំហំ ២៥ ម៉ែត្រ គុណ ១២០ ម៉ែត្រ ស្ថិតនៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម តែក្រោយមកនៅឆ្នាំ២០២២ ពួកខ្ញុំក៏បានលក់ដីមួយកន្លែងនោះ ដោយបានទឹកប្រាក់ចំនួន ២៩,០០០ (ពីរម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ហើយបានឯកភាពគ្នាដក់ប្រាក់ចំនួន ៤០០០ (បួនពាន់) ដុល្លារអាមេរិក សម្រាប់ថ្លៃសេវាផ្ទេរសិទ្ធិកាន់កាប់ ហើយប្រាក់ដែលនៅសល់គឺចំនួន ២៥,០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ហើយប្រាក់ចំនួន ២៥,០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិកនេះ នាងខ្ញុំបានឱ្យទៅចុងចម្លើយរកស៊ីចងការប្រាក់ ហើយចំណែកការប្រាក់ដែលចុងចម្លើយទទួលបានគឺគាត់បានឱ្យមកខ្ញុំជារៀងរាល់ខែ។ ហេតុនេះប្រាក់ចំនួន ២៥,០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដែលជាទ្រព្យសម្បត្តិរួម គឺនាងខ្ញុំសុំទាមទារចំនួនពាក់កណ្ដាលស្មើគ្នា។

ខ. ការអះអាងរបស់ចុងចម្លើយ៖ ចំពោះប្រាក់ចំនួន **២៥,០០០ (ពីរម៉ឺនប្រាំពាន់)** ដុល្លារអាមេរិកនោះ ខ្ញុំបានទទួលយកទៅដាក់ចងការឱ្យគេប្រហែលចំនួន ៨,០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក ប៉ុណ្ណោះ ហើយប្រាក់ដែលនៅសល់គឺខ្ញុំទុកខ្លះ ប្រពន្ធទុកខ្លះ និងទិញរបស់របរដូចជា ចិញ្ចៀន ខ្សែករ ទូរស័ព្ទ កុំព្យូទ័រ និងសម្ភារប្រើប្រាស់ផ្សេងៗទៀតដែលខ្ញុំបាទមិនចាំចំនួននោះទេ។

**ខ.៤.៤. ស្ដីពីចំណុចវិវាទទី៤៖ អំពីអាហារកាតព្វកិច្ចបង់ផ្ដាច់ចិញ្ចឹមកូន**

ក. ការអះអាងរបស់ដើមចោទ៖ នាងខ្ញុំសូមទាមទារអាហារកាតព្វកិច្ចបង់ផ្ដាច់សម្រាប់ចិញ្ចឹមកូនពីចុងចម្លើយឈ្មោះ [redacted] សំអុល ចំនួន **៣០,០០០,០០០ (សាមសិបលាន)** រៀល ហើយប្រាក់ទាំងនេះគឺនាងខ្ញុំយកមកសម្រាប់ផ្គត់ផ្គង់លើការសិក្សា និងចិញ្ចឹមកូនស្រីរបស់នាងខ្ញុំ។

ខ. ការអះអាងរបស់ចុងចម្លើយ៖ ខ្ញុំបាទមិនឯកភាពទេ ព្រោះខ្ញុំមិនឯកភាពលែងលះជាមួយប្រពន្ធឡើយ។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យអំពីការទាមទារឱ្យលែងលះ

#### ក.១. ការទទួលស្គាល់អង្គហេតុ

សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ១៤ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៨ របស់រដ្ឋបាលឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល តុលាការទទួលស្គាល់ថា ដើមចោទ និងចុងចម្លើយ គឺជាប្ដីប្រពន្ធ។ ការណ៍ដែលដើមចោទទាមទារលែងលះ គឺជាសិទ្ធិទាមទារឱ្យសិទ្ធិទាមទារឱ្យលែងលះរបស់ប្ដីប្រពន្ធតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។

#### ក.២. ការវិនិច្ឆ័យ

តាមភស្តុតាងក្នុងសំណុំរឿង អង្គហេតុដែលជាមូលហេតុនៃការលែងលះ គឺជាមូលហេតុនៃការលែងលះតាមមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ង នៃក្រមរដ្ឋប្បវេណី ដែលតុលាការពិនិត្យឃើញថា ដើមចោទលែងមានមនោសញ្ចេតនាចំពោះចុងចម្លើយបន្តទៀតហើយ ជាហេតុធ្វើឱ្យចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយ មិនអាចបន្តទៀតបាន និងមិនអាចធ្វើបដិទានឡើងវិញបានឡើយ។ ហេតុនេះ តុលាការនឹងសម្រេចទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការលែងលះ ដោយឱ្យដើមចោទលែងលះចុងចម្លើយ។



Scanned with CamScanner

ខ. ការវិនិច្ឆ័យអំពីការទាមទារសិទ្ធិអំណាចមេបាលើកូន ក្រោយការលែងលះ

ខ.១. ការទទួលស្គាល់អង្គហេតុ

តាមសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ៤៦ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ នៃសៀវភៅកំណើតលេខ ០១/២០១៨ របស់រដ្ឋបាលឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បញ្ជាក់ថា ឈ្មោះ [redacted] យ៉ានីន ភេទស្រី កើតថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ គឺជាកូនរបស់ដើមចោទ និងចុងចម្លើយ។

ខ.២. ការវិនិច្ឆ័យ

គិតត្រឹមកាលបរិច្ឆេទនៃពាក្យបណ្តឹងលែងលះ ឈ្មោះ [redacted] យ៉ានីន ភេទស្រី គឺជាអនីតិជន ដែលស្ថិតនៅក្នុងវ័យនៃការថែទាំ ក្នុងកម្រិតអតិបរមានៃការរក្សាផលប្រយោជន៍របស់កុមារ។ បើពិនិត្យអំពីស្ថានភាពនៃអាយុកុមារ ធៀបទៅនឹងមូលហេតុនៃការលែងលះដែលបានអះអាងដោយដើមចោទ និងដែលត្រូវបានទទួលស្គាល់ដោយតុលាការ តុលាការពិនិត្យឃើញថា រវាងដើមចោទ និងចុងចម្លើយ ការកំណត់យកដើមចោទ គឺជាអ្នកមានអំណាចមេបាក្រោយការលែងលះលើឈ្មោះ [redacted] យ៉ានីន មានភាពល្អប្រសើរជាងការកំណត់យកចុងចម្លើយជាអ្នកមានអំណាចមេបាក្រោយការលែងលះលើឈ្មោះ [redacted] យ៉ានីន ព្រោះតាមអង្គហេតុដែលជាមូលហេតុនៃការលែងលះ ដើមចោទអាចផ្តល់លទ្ធភាពនៃការរស់នៅ និងការចិញ្ចឹមបីបាច់ថែរក្សាកូនបានប្រសើរជាងចុងចម្លើយ ហេតុនេះ តុលាការនឹងសម្រេចកំណត់យកដើមចោទ គឺជាអ្នកមានអំណាចមេបាក្រោយការលែងលះលើឈ្មោះ [redacted] យ៉ានីន ភេទស្រី។

គ. ការវិនិច្ឆ័យអំពីការទាមទារឱ្យបង់ផ្តាច់អាហារកាតព្វកិច្ចចិញ្ចឹមកូន

គ.១. ការទទួលស្គាល់អង្គហេតុ

ដោយតុលាការសម្រេចយកដើមចោទជាអ្នកមានអំណាចមេបាក្រោយការលែងលះ ហេតុនេះ តាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ចុងចម្លើយដែលជាឪពុកដែលពុំមានអំណាចមេបាលើកូនក្រោយការលែងលះត្រូវមានកាតព្វកិច្ចក្នុងការបង់សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន។

គ.២. ការវិនិច្ឆ័យ

តាមការទាមទាររបស់ដើមចោទ តុលាការយល់ឃើញថា សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន មិនអាចធ្វើការទាមទារឱ្យចុងចម្លើយដែលជាឪពុកដែលពុំមានអំណាចមេបាលើកូនក្រោយការលែងលះ ធ្វើការបង់ផ្តាច់បាននោះទេ ប៉ុន្តែសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនចុងចម្លើយត្រូវបង់ជារៀងរាល់ខែឱ្យទៅដើមចោទ ក្នុងទំហំសមរម្យ ដែលអាចធានាបាននូវផលប្រយោជន៍ជាអប្បបរមារបស់កូន។ តុលាការសម្រេចឱ្យចុងចម្លើយបង់សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនចំនួន ៤០០.០០០ (សែសិបម៉ឺន) រៀល ក្នុងមួយខែ ឱ្យទៅដើមចោទរហូតដល់កូនពេញនីតិភាព។

ឃ. ការវិនិច្ឆ័យអំពីការទាមទារឱ្យបែងចែកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

ដើមចោទទាមទារឱ្យតុលាការធ្វើការបែងចែកទ្រព្យសម្បត្តិជាទឹកប្រាក់ចំនួន **២៥,០០០ (ពីរម៉ឺនប្រាំពាន់)** ដុល្លារអាមេរិក ដែលដើមចោទ និងចុងចម្លើយអះអាងថា ជាទ្រព្យសម្បត្តិរួមដែលបានពីការលក់អចលនវត្ថុ។



Scanned with CamScanner

តុលាការពិនិត្យឃើញថា ដើមចោទ និងចុងចម្លើយ ពុំមានភស្តុតាណាមួយដែលអាចបញ្ជាក់អំពីចំនួនទឹកប្រាក់ខាងលើនេះទេ ហេតុនេះ តុលាការមិនទទួលស្គាល់ការទាមទារឱ្យបែងចែកទ្រព្យសម្បត្តិរួមខាងលើនេះទេ។

**ង. អំពីបន្ទុកនៃការប្រាក់ប្រដាប់ក្តី**

**យល់ឃើញថា** តាមមាត្រា ៦៤ មាត្រា ១៨២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការនឹងសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី នៅសាលាដំបូងឱ្យជាបន្ទុករបស់ចុងចម្លើយ។

**សេចក្តីសម្រេចចបព្ចប់**

ក. លែងលះដើមចោទឈ្មោះ [redacted] **ស្រីនិច្ច** និងចុងចម្លើយឈ្មោះ [redacted] **សំអុល**។

ខ. កំណត់យកដើមចោទឈ្មោះ [redacted] **ស្រីនិច្ច** ជាអ្នកមានអំណាចមេបាលើកូនស្រី រវាងដើមចោទ និងចុងចម្លើយ ដែលមានឈ្មោះ [redacted] **យ៉ានីន** ភេទស្រី កើតថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ដែលមានសៀវភៅកំណើតលេខ ៤៦ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ នៃសៀវភៅកំណើតលេខ ០១/២០១៨ របស់រដ្ឋបាលឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

គ. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **សំអុល** បង់សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនជាប្រាក់ចំនួន **៤០០.០០០ (សែសិបម៉ឺន) រៀល** ក្នុងមួយខែ ឱ្យទៅដើមចោទឈ្មោះ [redacted] **ស្រីនិច្ច** គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះ ចូលជាស្ថាពររហូតដល់ឈ្មោះ [redacted] **យ៉ានីន** ដែលបានកត់ត្រាក្នុងចំណុច ខ ខាងលើនេះ ក្លាយជានីតិជន។

ឃ. ច្រានចោលការទាមទារក្នុងចំណុចទី៣ នៃពាក្យបណ្តឹងរបស់ដើមចោទ។

ង. ប្រាក់ប្រដាប់ក្តីនៅជាន់សាលាដំបូង ជាបន្ទុករបស់ចុងចម្លើយ។

ថ្ងៃ ពុធ ១៤ កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ខេត្តកណ្តាល,ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ១៤ កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្តាល, ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

**បានឃើញ**

**ចៅក្រម**

**ក្រឡាបញ្ជី**

[redacted]

[redacted]



Scanned with CamScanner